អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



# កណ្ដុរទីក្រុងនិងកណ្ដុរស្រុកស្រែ

# The Country Mouse And The City Mouse


**កែសម្រួលដោយ TukTuk**

**រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ**

**Seinan Jo Gakuin ប្រទេសជប៉ុន**


**សូមស្កេនQR CODE**

គំនូរជីវចល    ធនធានបង្រៀន


**Translated by TukTuk   Illustrated by a Japanese student of Seinan Jogakuin University**



កាលពីព្រេងនាយ មានកណ្ដុរពីរក្បាលជាសម្លាញ់នឹងគ្នា។ ថ្ងៃមួយកណ្ដុរទីក្រុងបានមកលេងកណ្ដុរស្រុកស្រែ។ កណ្ដុរស្រុកស្រែពិតជាសប្បាយចិត្តខ្លាំងណាស់ ហើយបានរៀបចំម្ហូបអាហារសាមញ្ញបែបស្រុកស្រែ ដើម្បីទទួលកណ្ដុរទីក្រុង។



«ហូបឱ្យឆ្អែតទៅសម្លាញ់ កុំខ្លាចចិត្តខ្ញុំអី»។ ម្ហូបមានទឹកគ្រឿង ហហ្មុក (អាម៉ុក) បាយនិងផ្លែឈើជាដើម។ កណ្ដុរទីក្រុងបានឃើញហើយក៏និយាយ «អូ ព្រះអើយ! តើឯងចូលចិត្តហូបអាហារសាមញ្ញបែបហ្នឹង? ហេតុអ្វីបានជាឯងមិនសាកទៅទីក្រុងម្ដងមើល? ព្រោះទីនោះមានអាហារឆ្ងាញ់ៗច្រើនណាស់»។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



កណ្ដុរស្រុកស្រែបានសម្រេចចិត្តទៅលេងទីក្រុងម្ដង។ ទីក្រុងពិតជាធំខ្លាំងណាស់ហើយមានរ៉ឺម៉កកង់បីពាសពេញហ្នឹងតែម្ដង «ឆាប់ឡើងៗវាមានគ្រោះថ្នាក់ណាស់ កុំដើរយឺតពេក» កណ្ដុរទីក្រុងនិយាយ។ កណ្ដុរស្រុកស្រែក៏ដើរតាមផ្លូវទាំងអារម្មណ៍ភ័យខ្លាចនិងស្រឡាំងកាំង។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



កណ្តុរទីក្រុងនិយាយ «ពួកយើងបានមកដល់ផ្ទះដែលខ្ញុំរស់នៅហើយ»។ កណ្តុរស្រុកស្រែបានចូលទៅក្នុងផ្ទះបាយក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំងតែម្តង។ នៅលើតុអាហារមានសុទ្ធតែម្ហូបអាហារប្លែកៗ ដែលវាមិនដែលបានឃើញពីមុនមកនោះទេ។ កណ្តុរស្រុកស្រែលាន់មាត់ «អូ! ពិតជាអស្ចារ្យខ្លាំងណាស់»។




កណ្ដុរទីក្រុងនិយាយ «ហូបឱ្យច្រើនៗទៅសម្លាញ់ កុំក្រែងចិត្តអីណា»។
កណ្ដុរទាំងពីរកំពុងហូបសុខៗ ស្រាប់តែឮស្នូរជើងនរណាម្នាក់បានដើរចូលមក។
កណ្ដុរទីក្រុងនិយាយ «ពួកយើងជួបអាសន្នហើយ គស់! ទៅរកកន្លែងលាក់ខ្លួនសិន»។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



«ពួកយើងត្រូវលាក់ខ្លួនឱ្យស្ងៀមស្ងាត់រហូតដល់មនុស្សចេញសិន ប្រសិនបើមិនដូច្នេះទេ ពួកយើងនឹងត្រូវគេដេញចាប់ហើយ»។ «មនុស្សចេញហើយ ពួកយើងហូបអាហារបន្ត!»។



កណ្ដុរទាំងពីរបានឡើងទៅលើតុបាយម្ដងទៀត។ បន្ទាប់មក ពួកគេបានឮស្នូរជើងមនុស្សចូលមកទៀតហើយ។
«ពួកយើងជួបអាសន្នទៀតហើយ តស់! ទៅលាក់ខ្លួនម្ដងទៀតសិន!»។
ពួកគេទាំងពីរពិតជាឃ្លានខ្លាំងណាស់ តើពួកគេត្រូវលាក់ខ្លួនបែបនេះប៉ុន្មានដងទៀត?
កណ្ដុរស្រុកស្រែភ័យខ្លាចនិងមិនស្ងប់ចិត្តនោះទេ។



«ឥឡូវនេះយើងអាចចេញបានហើយ ដូច្នេះឯងហូបបានតាមសប្បាយ ចង់ហូបប៉ុណ្ណាក៏បានដែរ»។
«កុំបារម្ភណ៍អីណា ខ្ញុំនឹងហូបវាឱ្យច្រើនៗតែម្តង»។  ប៉ុន្តែភ្លាមៗនោះ កណ្តុរស្រុកស្រែអស់កម្លាំងជាខ្លាំង។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



កណ្ដុរទីក្រុងសួរ «ហេតុអ្វីបានជាសម្លាញ់ឆាប់ត្រលប់ទៅផ្ទះម្ល៉េះ តើអាហារមិនឆ្ងាញ់ ឬហូបមិនឆ្អែត?»។ «ខ្ញុំចង់រស់នៅស្រុកស្រែវិញ ទោះបីជាពួកយើងមិនមានម្ហូបអាហារល្អពិសេសក៏ពិតមែនតែពួកយើងអាចហូបបានដោយមិនមានភាពភ័យខ្លាច»។ កណ្ដុរស្រុកស្រែបានលាសម្លាញ់របស់វា «លាហើយសម្លាញ់ ខ្ញុំត្រលប់ទៅផ្ទះស្រុកស្រែវិញហើយ»។ ពួកគេទាំងពីររស់នៅមានក្ដីសុខដូចគ្នា គ្រាន់តែតាមរបៀបផ្សេងគ្នាប៉ុណ្ណោះ។